ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៥ សសរ

# សេចក្តីសម្រេច
# ស្តីពី
# សមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមសំណើរបស់ប្រធានគណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១** ..

សេចក្តីសម្រេចនេះ កំណត់អំពីសមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការអន្តរ-ក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩។

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សរសេរជាអក្សរកាត់ថា "**គ.អ.ក.**" មាន សមាសភាព ដូចខាងក្រោម៖

១- ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធាន

២- ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អនុប្រធានអចិន្ត្រៃយ៍

៣- ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុប្រធាន

៤- ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ អនុប្រធាន

៥- ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ឺុង សំផន** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

៦- ឯកឧត្តម **សយ សុខា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៧- ឯកឧត្តម **អ៊ុច បូររិទ្ធ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៨- ឯកឧត្តម **ខឿរី វិសុត្ត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៩- លោកជំទាវវេជ្ជបណ្ឌិត **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

១០-ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន

១១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក អនុប្រធាន

១២-ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៣-ឯកឧត្តម **វ៉ាន់ សុធី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៤-លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៥-លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៦-លោកជំទាវវេជ្ជបណ្ឌិត **ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១៧-ឯកឧត្តមសាស្ត្រាចារ្យ **ហ៊ុន ចំរើន** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១៨-ឯកឧត្តមវេជ្ជបណ្ឌិត **ឡូ វាសនាគិរី** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១៩-ឯកឧត្តមវេជ្ជបណ្ឌិត **ង៉ូវ កាង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

២០-ឯកឧត្តម **នេត្រ ភ័ក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

២១-ឯកឧត្តម **ហ៊ីង ជននាថ** រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២២-ឯកឧត្តម **រស់ វណ្ណា** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

២៣-ឯកឧត្តម **ទិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

២៤-ឯកឧត្តម **ហេង សួរ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៥-ឯកឧត្តម **គឹម សន្តិភាព** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

២៦-ឯកឧត្តម **ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

២៧-ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

២៨-ឯកឧត្តម **ខូច មករា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

២៩-ឯកឧត្តម **ជា អូន** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

៣០-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៣១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវបារកិច្ចក្រសួងការពារជាតិ សមាជិក

៣២-ឯកឧត្តមនាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

៣៣-ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត សមាជិក

៣៤-ឯកឧត្តម **ហុក គឹមចេង** អគ្គនាយកបច្ចេកទេសសុខាភិបាលក្រសួងសុខាភិបាល សមាជិក

៣៥-ឯកឧត្តម **សុខ សំអាង** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុក្រសួងសុខាភិបាល សមាជិក។

**គ.អ.ក.** ត្រូវអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ២** ..

**គ.អ.ក.** មានគណៈប្រតិបត្តិមួយ ដែលជាយន្តការដឹកនាំ និងសម្របសម្រួលការងារប្រចាំថ្ងៃទាក់ទងនឹងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់ **គ.អ.ក.** និងសម្របសម្រួលការអនុវត្តវិធានការប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត។

គណៈប្រតិបត្តិនៃ **គ.អ.ក.** មានសមាសភាព ដូចខាងក្រោមៈ

១-ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធាន

២-ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុប្រធាន

៤-ឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥-ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន

៦-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក អនុប្រធាន

៧-ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៨-ឯកឧត្តម **វាន់ សុធី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៩-លោកជំទាវវេជ្ជបណ្ឌិត **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១០-លោកជំទាវវេជ្ជបណ្ឌិត **ឱ វណ្ណារិន** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១១-ឯកឧត្តមសាស្ត្រាចារ្យ **ហ៊ិន ចំរើន** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១២-ឯកឧត្តមវេជ្ជបណ្ឌិត **ឡូ វាសនាគិរី** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១៣-ឯកឧត្តម **ហេង សួរ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៤-ឯកឧត្តម **គឹម សន្តិភាព** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១៥-ឯកឧត្តម **ជិន ម៉ាលីន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១៦-ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១៧-ឯកឧត្តម **ខូវ មករា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

១៨-ឯកឧត្តម **កុល ធីរភក្ត្រ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១៩-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ិន ម៉ានិត** អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ សមាជិក

២០-ឯកឧត្តមនាយឧត្តមសេនីយ៍ **ខេង សុមេធ** អគ្គស្នងការរងនគរបាលជាតិ សមាជិក

២១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឌី ទិដ្ឋា** អគ្គស្នងការរងនគរបាលជាតិ សមាជិក។

គណៈប្រតិបត្តិនៃ **គ.អ.ក.** មានតួនាទី និងភារកិច្ច ព្រមទាំងកិច្ចដំណើរការ ដូចមានចែងក្នុងមាត្រា៨ និងមាត្រា៩ នៃអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ៣ ..**

**គ.អ.ក.** មានអនុគណៈកម្មការ ចំនួន ១០ (ដប់) ដូចខាងក្រោម៖

១-អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ

២-អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក

៣-អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩

៤-អនុគណៈកម្មការបច្ចេកទេស និងព្យាបាល

៥-អនុគណៈកម្មការសេវាមន្ទីរពិសោធន៍

៦-អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ

៧-អនុគណៈកម្មការបច្ចេកវិទ្យា និងទិន្នន័យ

៨-អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

៩-អនុគណៈកម្មការសាងសង់ និងជួសជុល និង

១០-អនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩។

**ប្រការ៤ ..**

ប្រព័ន្ធដឹកនាំសម្របសម្រួលការងាររបស់គណៈប្រតិបត្តិនៃ **គ.អ.ក.** លើការអនុវត្តការងាររបស់អនុគណៈកម្មការនីមួយៗចំណុះឱ្យ **គ.អ.ក.** ត្រូវបានរៀបចំ ដូចខាងក្រោម៖

១-ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** ប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុកដឹកនាំរួម និង ទទួលបន្ទុកអនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩

២-ឯកឧត្តម **កើត រិទ្ធ** អនុប្រធានអចិន្ត្រៃយ៍គណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុកអនុគណៈកម្មការ វាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ និងអនុគណៈកម្មការសេវាមន្ទីរពិសោធន៍

៣-ឯកឧត្តម **ជា វ៉ាន់ដេត** អនុប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុកអនុគណៈកម្មការបច្ចេកវិទ្យា និងទិន្នន័យ និងអនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ

៤-ឯកឧត្តម **វង្សី វិស្សុត** អនុប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុកអនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងអនុគណៈកម្មការសាងសង់ និងជួសជុល

៥-ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អនុប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុកអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក និង

៦-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អនុប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ទទួលបន្ទុក អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ និងអនុគណៈកម្មការ បច្ចេកទេស និងព្យាបាល។

**ប្រការ៥** .-

អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ មានភារកិច្ច ដូចខាងក្រោម៖

- វាយតម្លៃសភាពការណ៍វិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ដើម្បីដាក់ចេញវិធានការឆ្លើយតបឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- រៀបចំផែនការឆ្លើយតបនឹងជំងឺកូវីដ-១៩ ទៅតាមការវិវត្តនៃការឆ្លងដាលរាលនៃជំងឺកូវីដ-១៩
- លើកសំណើវិធានការ និងទិសដៅប្រតិបត្តិតាមស្ថានភាពជាក់ស្តែងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ វាយតម្លៃ និងលើកសំណើផែនការ និងវិធានការនានា ដើម្បីបើកដំណើរការឡើងវិញនូវសកម្មភាពតាមវិស័យ និងអនុវិស័យនីមួយៗ
- ផ្តល់ការណែនាំ និងការពិគ្រោះយោបល់ដល់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទាក់ទងនឹងវិធានការ ទាំងវិធានការសុខាភិបាល ទាំងវិធានការរដ្ឋបាល ដែលត្រូវអនុវត្តក្នុងការប្រយុទ្ធទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការផ្សេងទៀតដែលចំណុះឱ្យ **គ.អ.ក.** ត្រូវផ្តល់នូវកិច្ចសហការ ទិន្នន័យ និងព័ត៌មានចាំបាច់នានា ដល់អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្ត្រ ដើម្បីឱ្យអនុគណៈកម្មការនេះអាចអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តមវេជ្ជបណ្ឌិត ឡូ វាសនាគិរី** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ក**។

**ប្រការ៦** ..

អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលការអនុវត្តវិធានការក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមបណ្តាច្រកទ្វារព្រំដែនគោក ព្រំដែនទឹក និងច្រកចេញ-ចូលតាមផ្លូវអាកាស នៅទូទាំងប្រទេស
- ដឹកនាំ និងសម្របសម្រួលការអនុវត្តវិធានការត្រួតពិនិត្យសុខភាព និងការយកសំណាកវិភាគរកមេរោគកូវីដ-១៩ លើរាល់អ្នកដំណើរទាំងអស់ដែលធ្វើដំណើរចូលក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំ និងដឹកនាំអនុវត្តវិធានការដោយឡែកដើម្បីត្រួតពិនិត្យសុខភាព និងការយកសំណាកវិភាគរកមេរោគកូវីដ-១៩ លើអ្នកដំណើរមកពីតំបន់ដែលមានការផ្ទុះការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បំប្លែងខ្លួនថ្មី ឬតំបន់ដែលមានហានិភ័យខ្ពស់ផ្សេងទៀត
- ដាក់ចេញនូវវិធានការឆ្លើយតបបន្ទាន់ ក្នុងករណីដែលរកឃើញថា អ្នកដំណើរមានផ្ទុកមេរោគកូវីដ-១៩ ឬសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ ដោយអនុវត្តតាមគោលការណ៍ផ្នែកសុខាភិបាល និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធ
- ដឹកនាំ និងសម្របសម្រួលការអនុវត្តវិធានការគ្រប់គ្រង និងដឹកជញ្ជូនអ្នកដំណើរ ដើម្បីអនុវត្តវិធានការចត្តាឡីស័ក និង/ឬ វិធានការផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន
- កំណត់ រៀបចំ និងគ្រប់គ្រងទីកន្លែងធ្វើចត្តាឡីស័ក សម្រាប់អ្នកដំណើរដែលធ្វើដំណើរចូលក្នុងព្រះរាជាណាចក្រកម្ពុជាតាមផ្លូវអាកាស ដោយសហការជាមួយនឹងយន្តការពាក់ព័ន្ធជាធរមាន
- ដឹកនាំការសម្របសម្រួលការគ្រប់គ្រងទីកន្លែងធ្វើចត្តាឡីស័ក សម្រាប់អ្នកដំណើរដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជា តាមបណ្តាច្រកទ្វារព្រំដែនគោក និងព្រំដែនទឹក ដោយសហការជាមួយគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត
- ដឹកនាំ និងសម្របសម្រួលការធ្វើចត្តាឡីស័ក និងគ្រប់គ្រងទីកន្លែងធ្វើចត្តាឡីស័ក សម្រាប់បុគ្គលដែលមានការពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលជាមួយបុគ្គលដែលមានផ្ទុកមេរោគកូវីដ-១៩ ដែលបានរកឃើញ ដោយសហការជាមួយនឹងអនុគណៈកម្មការដែលមានការពាក់ព័ន្ធ និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- ពង្រឹងការអនុវត្តវិធានការសុខាភិបាលនានានៅតាមបណ្តាច្រកទ្វារព្រំដែនគោក ព្រំដែនទឹក និងច្រកចេញ-ចូលតាមផ្លូវអាកាស នៅទូទាំងប្រទេស ជាពិសេស កាតព្វកិច្ចពាក់ម៉ាស, ការរក្សាគម្លាតសុវត្ថិភាព និងការធ្វើអនាម័យសម្លាប់មេរោគសំដៅបង្ការការឆ្លង និងការចម្លងមេរោគកូវីដ-១៩
- រៀបចំផែនការសកម្មភាពក្នុងការគ្រប់គ្រងការនាំចូលជំងឺកូវីដ-១៩ នៅតាមច្រកទ្វារព្រំដែនគោក ព្រំដែនទឹក និងច្រកចេញ-ចូលតាមផ្លូវអាកាស និងការធ្វើចត្តាឡីស័ក ដើម្បីធានាប្រសិទ្ធភាពក្នុងការ

ប្រយុទ្ធ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- រៀបចំទីកន្លែងសម្រាប់ធ្វើចត្តាឡីស័កឱ្យបានសមស្របទៅតាមស្ថានភាពវិវត្តនៃជំងឺកូវីដ-១៩ ដោយត្រូវរៀបចំដាក់អ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ឱ្យនៅដាច់ដោយឡែកពីបុគ្គលធ្វើចត្តាឡីស័កផ្សេងទៀត
- គ្រប់គ្រងការងារធ្វើចត្តាឡីស័ក និងទីកន្លែងធ្វើចត្តាឡីស័ក ដើម្បីធានាបាននូវការអនុវត្តយ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពនូវវិធានការធ្វើចត្តាឡីស័ក
- ប្រមូលទិន្នន័យអ្នកដំណើរតាមជើងយន្តហោះ (Manifest) និងសម្របសម្រួលដល់ការងារចត្តាឡីស័កក្នុងបរិវេណអាកាសយានដ្ឋានអន្តរជាតិ
- ដឹកនាំ និងសម្របសម្រួលការអនុវត្តវិធានការក្នុងការបញ្ជូនអ្នកដំណើរដែលមានផ្ទុកមេរោគកូវីដ-១៩ ទៅមណ្ឌលព្យាបាល និងអ្នកដំណើរដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ ទៅមណ្ឌល ឬទីកន្លែងធ្វើចត្តាឡីស័ក និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ិន ម៉ានិត** អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ក.**។

**ប្រការ៧.-**

អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ មានភារកិច្ចដូចខាងក្រោម៖
- តាមដានសភាពការណ៍ទូទៅនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដើម្បីស្រាវជ្រាវ និងប្រមូលព័ត៌មានទាក់ទងនឹងបុគ្គលមានផ្ទុកមេរោគកូវីដ-១៩
- ដឹកនាំ សម្របសម្រួល និងចាត់រាល់វិធានការចាំបាច់ ដើម្បីបម្រើដល់ការស្វែងរកឱ្យបានឆាប់រហ័សនូវករណីនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ដឹកនាំផ្ទាល់ ឬដឹកនាំសម្របសម្រួលប្រតិបត្តិការឆ្លើយតបបន្ទាន់ ដើម្បីគ្រប់គ្រងឧប្បត្តិហេតុនៃផ្ទុះឆ្លងរាលដាលនៃជំងឺកូវី-១៩ នៅទីតាំង ឬតំបន់ណាមួយ ដោយសហការជាមួយយន្តការដែលមានការពាក់ព័ន្ធ និងដោយអនុវត្តស្របតាមបទប្បញ្ញត្តិជាធរមាន
- ស្រាវជ្រាវ កំណត់អត្តសញ្ញាណ និងអាសយដ្ឋានរបស់បុគ្គលដែលមានផ្ទុកមេរោគកូវីដ-១៩ និងបុគ្គលដែលពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលជាមួយបុគ្គលដែលមានផ្ទុកមេរោគកូវីដ-១៩ ដែលត្រូវបានរកឃើញ
- គ្រប់គ្រង និងវាយតម្លៃសភាពការណ៍វិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ដើម្បីដាក់ចេញវិធានការឆ្លើយតបឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព សំដៅកាត់ផ្តាច់ និងគ្រប់គ្រងឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា នូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ស្រាវជ្រាវកំណត់ទីតាំងនានាដែលបុគ្គលដែលទើបរកឃើញផ្ទុកមេរោគកូវីដ-១៩ កំពុងស្នាក់នៅ និងធ្លាប់ស្នាក់នៅ, ទីកន្លែងធ្វើការរបស់បុគ្គលនោះ និងទីកន្លែងដែលបុគ្គលនោះធ្លាប់ទៅ ឬឧស្សាហ៍ទៅ

- សម្ភាសន៍បុគ្គលផ្ទុកមេរោគកូវីដ-១៩ អំពីព័ត៌មាននៃការធ្វើដំណើរ, ការស្នាក់នៅ និងការប្រាស្រ័យទាក់ទង
- ស្វែងរកបុគ្គលដែលទើបរកឃើញផ្ទុកមេរោគកូវីដ-១៩ ឬសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ ឬបុគ្គលដែលធ្លាប់មានទំនាក់ទំនងផ្ទាល់ និងដោយប្រយោលជាមួយបុគ្គលមានផ្ទុកមេរោគកូវីដ-១៩ ដែលបានរត់គេចខ្លួន
- ស្រាវជ្រាវទិន្នន័យអ្នកដំណើរចេញ-ចូលប្រទេស និងថតចម្លងលិខិតឆ្លងដែន សលាកប័ត្រអន្តោប្រវេសន៍របស់បុគ្គលផ្ទុកមេរោគកូវីដ-១៩ និងបុគ្គលពាក់ព័ន្ធ
- សហការជាមួយបណ្តាស្ថានទូត និងស្ថានតំណាងបរទេស ដើម្បីប្រមូលព័ត៌មានអ្នកឆ្លងជំងឺកូវីដ-១៩ ដែលធ្លាប់ស្នាក់នៅព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួល និងចាត់វិធានការយកសំណាកបុគ្គលដែលមានការសង្ស័យ និងបុគ្គលដែលធ្លាប់មានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយបុគ្គលមានផ្ទុកមេរោគកូវីដ-១៩ ឱ្យបានលឿន និងឆាប់រហ័ស ដើម្បីវិភាគរកមេរោគកូវីដ-១៩ ដោយការធ្វើតេស្តរហ័ស ឬយកទៅវិភាគរកមេរោគកូវីដ-១៩ នៅមន្ទីរពិសោធន៍
- ប្រមូលព័ត៌មានពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ តាមបណ្តាប្រទេសដែលមានពលករកម្ពុជាធ្វើការងារ
- ចងក្រងករណីនីមួយៗជារបាយការណ៍ និងថែរក្សាទុកទិន្នន័យដែលប្រមូលបានដោយរក្សាការសម្ងាត់ ដើម្បីជូនថ្នាក់ដឹកនាំ និងដើម្បីប្រើប្រាស់តាមការចាំបាច់
- សម្របសម្រួលបញ្ជូនអ្នកជំងឺកូវីដ-១៩ ដែលត្រូវបានរកឃើញ ទៅកន្លែងព្យាបាល ឬសម្របសម្រួលបញ្ជូនបុគ្គលដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ ទៅមណ្ឌល ឬទីកន្លែងធ្វើចត្តាឡីស័ក ដោយអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។ ចំពោះអ្នកជំងឺកូវីដ-១៩ ដែលត្រូវបានអនុញ្ញាតឱ្យព្យាបាលនៅតាមផ្ទះ ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីជាធរមាន
- សម្របសម្រួល, រៀបចំ និងគ្រប់គ្រងទីតាំងសម្រាប់ការយកសំណាក ដោយសហការជាមួយនឹងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ដោយធានាឱ្យបាននូវរបៀបរៀបរយ និងសណ្តាប់ធ្នាប់ ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងអំឡុងពេលនៃការយកសំណាក
- ស្រាវជ្រាវប្រមូលព័ត៌មាន និងវិភាគរកមូលហេតុនៃឧប្បត្តិហេតុនៃការផ្ទុះឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សម្រាប់ករណីនីមួយៗ ដើម្បីជាមូលដ្ឋានក្នុងការសិក្សា និងរៀបចំវិធានការឆ្លើយតបឱ្យបានត្រឹមត្រូវ សំដៅធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺនេះនាពេលអនាគត និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តមឧត្តមសេនីយ៍ឯក ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិ និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ច.ក.**។

**ប្រការ៨**.-

អនុគណៈកម្មការបច្ចេកទេស និងព្យាបាល មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលការណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារទាក់ទងនឹងការគ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ ព្រមទាំងគោលការណ៍ណែនាំផ្នែកបច្ចេកទេសសុខាភិបាល ដែលមានការពាក់ព័ន្ធផ្សេងទៀត
- ដឹកនាំ និងសម្របសម្រួលជាមួយគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទាក់ទងនឹងផ្នែកបច្ចេកទេស និងការព្យាបាល
- គ្រប់គ្រងផ្នែកសេវាព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ទាំងរដ្ឋ និងឯកជន ដោយសហការជាមួយនឹងយន្តការរបស់រាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ព្រមទាំងដៃគូជាតិ និងអន្តរជាតិ
- ដឹកនាំសម្របសម្រួល និងរៀបចំទីតាំងសម្រាប់ព្យាបាលអ្នកជំងឺកូវីដ-១៩ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយសហការជាមួយអនុគណៈកម្មការសាងសង់ និងជួសជុល និងអនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- រៀបចំផែនការផ្នែកធនធានមនុស្ស ធនធានសម្ភារ ធនធានបរិក្ខារនិងឱសថ និងធនធានថវិកា ទាក់ទងនឹងសេវាព្យាបាលអ្នកជំងឺកូវីដ-១៩ ដើម្បីឆ្លើយតបទៅនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ទាំងក្នុងសភាពការណ៍ធម្មតា ទាំងក្នុងសភាពការណ៍បន្ទាន់
- ដឹកនាំ និងសម្របសម្រួលជាមួយគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទាក់ទងនឹងការអនុវត្ត "**នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ**" ជាពិសេស លក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាតឱ្យព្យាបាលនៅតាមផ្ទះ ការគ្រប់គ្រងក្នុងអំឡុងពេលនៃការព្យាបាលនៅតាមផ្ទះ និងការពិនិត្យតាមដានស្ថានភាពសុខភាពអ្នកជំងឺកូវីដ-១៩
- ដឹកនាំ សម្របសម្រួល ផ្តល់ការណែនាំ និងបណ្តុះបណ្តាលផ្នែកបច្ចេកទេសក្នុងការព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ព្រមទាំង "**នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ**" ដល់មន្ត្រី និងបុគ្គលិកសុខាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីប្រសិទ្ធភាពនៃការដាក់ឱ្យអនុវត្តការថែទាំ និងការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ
- ណែនាំការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមទីតាំងព្យាបាលជំងឺកូវីដ-១៩
- គ្រប់គ្រងការបង្ការ និងត្រួតពិនិត្យការចម្លងមេរោគកូវីដ-១៩ ដោយអនុវត្តវិធានការប្រកបដោយសុវត្ថិភាពនៅតាមទីតាំងព្យាបាលជំងឺកូវីដ-១៩
- ផ្តល់កិច្ចសហការ និងការគាំទ្រចាំបាច់នានាទាក់ទងនឹងសេវាព្យាបាល ថែទាំអ្នកជំងឺកូវីដ-១៩ នៅតាមបណ្តារាជធានី-ខេត្ត ដោយរួមទាំងសេវាព្យាបាល ថែទាំអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ
- សម្របសម្រួលការគ្រប់គ្រងការងារក្រោយការព្យាបាល និងថែទាំអ្នកជំងឺកូវីដ-១៩ ជាមួយនឹងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ដោយអនុវត្តតាមបទប្បញ្ញត្តិជាធរមាន
- ពិគ្រោះយោបល់ និងសម្របសម្រួលជាមួយគ្រប់ដៃគូពាក់ព័ន្ធលើកិច្ចការសហប្រតិបត្តិការផ្នែកបច្ចេកទេស និងការព្យាបាល ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ត្រួតពិនិត្យ, តាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពនៃការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅទូទាំងប្រទេស និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តមសាស្ត្រាចារ្យ ហ៊ិន ចំរើន** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ក.**។

**ប្រការ៩** .-

អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ មានភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងសេវាមន្ទីរពិសោធន៍ទាំងរដ្ឋ និងឯកជន នៅទូទាំងប្រទេស លើការងារពាក់ព័ន្ធនឹងជំងឺកូវីដ-១៩
- សិក្សា និងស្រាវជ្រាវអំពីការវិវត្តនៃមេរោគកូវីដ-១៩ និងមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ដើម្បីដាក់ចេញនូវវិធានការឆ្លើយតបឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព
- ប្រមូលព័ត៌មានទាក់ទងនឹងចំនួនអ្នកឆ្លងជំងឺកូវីដ-១៩ ថ្មីប្រចាំថ្ងៃ ចំនួនអ្នកជំងឺកូវីដ-១៩ ដែលកំពុងសម្រាកព្យាបាល ចំនួនអ្នកជាសះស្បើយពីជំងឺកូវីដ-១៩ និងអ្នកទទួលមរណភាពដោយសារជំងឺកូវីដ-១៩ ដើម្បីបូកសរុប និងរាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំ
- រៀបចំផែនការដើម្បីបង្កើនសមត្ថភាពមន្ទីរពិសោធន៍ និងចំនួនមន្ទីរពិសោធន៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ពិគ្រោះយោបល់ និងសម្របសម្រួលជាមួយគ្រប់ដៃគូពាក់ព័ន្ធលើកិច្ចការសហប្រតិបត្តិការដើម្បីធ្វើបច្ចុប្បន្នភាពសមត្ថភាពមន្ទីរពិសោធន៍ក្នុងការពិនិត្យរកមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**លោកជំទាវវេជ្ជបណ្ឌិត យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ក.**។

**ប្រការ១០** .-

អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំវគ្គបណ្តុះបណ្តាល និងធ្វើលំហាត់សមយុទ្ធ ដើម្បីផ្សព្វផ្សាយការយល់ដឹងដល់មន្ត្រីសុខាភិបាល និងផ្នែកពាក់ព័ន្ធ
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការទប់ស្កាត់, ការបង្ការ និងវិធាននានាចាំបាច់សម្រាប់ឆ្លើយតបទៅនឹងជំងឺកូវីដ-១៩
- រៀបចំ, ផ្សព្វផ្សាយ និងអប់រំដល់សាធារណជនអំពីវិធីសាស្ត្រនានាក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- រៀបចំ, ផ្សព្វផ្សាយ និងអប់រំដល់សាធារណជនអំពីរបៀបថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតស្រាល ដែលត្រូវបានអនុញ្ញាតឱ្យនៅដាច់ដោយឡែកនៅតាមលំនៅដ្ឋាន ឬទីសំណាក់របស់អ្នកជំងឺកូវីដ-១៩
- ផ្សព្វផ្សាយ និងអប់រំដល់សាធារណជនអំពីនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

- តាមដាន និងប្រមូលព័ត៌មានលើប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញសង្គមនានា ដើម្បីចាត់វិធានការឆ្លើយតបចាំបាច់នានាឱ្យបានទាន់ពេលវេលា ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើនសមត្ថភាពក្រុមឆ្លើយតបបន្ទាន់ និងរៀបចំប្រព័ន្ធទាន់ហេតុការណ៍ ដោយប្រើប្រាស់យន្តការពេញលេញដែលអាចវាយបកទៅគ្រប់ព័ត៌មានក្លែងក្លាយ និងព័ត៌មានប្រឌិត
- ផ្តល់ព័ត៌មានភ្លាមៗស្តីពីបច្ចុប្បន្នភាពនៃជំងឺ និងការឆ្លងរាលដាលនៃជំងឺក្នុងចំណោមអ្នកដំណើរទាំងជាតិ ទាំងអន្តរជាតិ និងសហគមន៍
- រក្សាទំនាក់ទំនងឱ្យបានទូលំទូលាយស្តីពីការទប់ស្កាត់ហានិភ័យ ដោយផ្តល់ព័ត៌មាន និងសារសំខាន់ៗទៅសាធារណជន និងផ្នែកពាក់ព័ន្ធដទៃទៀត
- តាមដានប្រព័ន្ធផ្សព្វផ្សាយជាតិ, អន្តរជាតិ, ព័ត៌មានទាន់ហេតុការណ៍, ព័ត៌មានត្រឡប់ពីអ្នកជំងឺ ដើម្បីកាត់បន្ថយនូវការព្រួយបារម្ភ និងការភិតភ័យពីប្រជាពលរដ្ឋ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**លោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ជ.ក.**។

## ប្រការ១១ _

អនុគណៈកម្មការបច្ចេកវិទ្យា និងទិន្នន័យ មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីចូលរួមបម្រើឱ្យការប្រយុទ្ធ ទប់ស្កាត់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យ និងព័ត៌មានទាំងឡាយទាក់ទងនឹងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាអាទិ៍ ទិន្នន័យអ្នកជំងឺកូវីដ-១៩, អ្នកធ្វើចត្តាឡីស័ក និងបុគ្គលដែលមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ដើម្បីបម្រើឱ្យការរៀបចំផែនការក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យ និងព័ត៌មានទាំងឡាយទាក់ទងនឹងកិច្ចការវ៉ាក់សាំងកូវីដ-១៩ ព្រមទាំងការងារពាក់ព័ន្ធផ្សេងទៀត ដើម្បីបម្រើឱ្យការរៀបចំផែនការវ៉ាក់សាំងកូវីដ-១៩
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាវិញ្ញាបនបត្រវ៉ាក់សាំងឆ្លាត ( Smart Vaccination Certificate )
- សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំទិន្នន័យមូលដ្ឋានជាតិ ដើម្បីគាំទ្រដល់ការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងសម្រាប់ពហុគោលបំណង
- រៀបចំប្រព័ន្ធរាយការណ៍តាមបែបបច្ចេកវិទ្យា ដើម្បីទទួលព័ត៌មានពីប្រជាពលរដ្ឋ ក្នុងករណីដែលមានការសង្ស័យថាមានករណីវិជ្ជមានជំងឺកូវីដ-១៩
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងធនធានមនុស្ស និងធនធានសម្ភារ និងបរិក្ខារ ដើម្បីបម្រើឱ្យការរៀបចំផែនការក្នុងការប្រយុទ្ធ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តម ខូវ មករា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ក**.។

**ប្រការ១២** .-

អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការធនធានមនុស្ស, ធនធានសម្ភារ ធនធានបរិក្ខារនិងឱសថ និងធនធានថវិកា ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងតម្រូវការក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយសហការជាមួយអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក**. និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- រៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- រៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងកិច្ចលទ្ធកម្ម ឱ្យកាន់មានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- រៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងសន្និធិទំនិញ សម្ភារ បរិក្ខារនិងឱសថ ឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ធានាការផ្គត់ផ្គង់ធនធានមនុស្ស, ធនធានសម្ភារ ធនធានបរិក្ខារនិងឱសថ និងធនធានថវិកា ដើម្បីបម្រើឱ្យការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- រៀបចំផែនការធនធានមនុស្ស, ធនធានសម្ភារ ធនធានបរិក្ខារនិងឱសថ និងធនធានថវិកា ដើម្បីឆ្លើយតបទាន់ពេលវេលាក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ផ្តល់ការផ្គត់ផ្គង់ចាំបាច់នានាដើម្បីគាំទ្រដល់ប្រតិបត្តិការការងាររបស់ **គ.អ.ក**. ព្រមទាំងអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក**. និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- បូកសរុប វាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំលើការអនុវត្តរបស់ **គ.អ.ក**. ក្នុងការគ្រប់គ្រង, ការប្រគល់-ទទួល ការប្រើប្រាស់ និងការបែងចែកធនធានថវិកា ធនធានសម្ភារ បរិក្ខារ និងឱសថក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ក**.។

អនុគណៈកម្មការនេះ ដឹកនាំដោយ**លោកជំទាវវេជ្ជបណ្ឌិត យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ក**.។

**ប្រការ១៣** .-

អនុគណៈកម្មការសាងសង់ និងជួសជុល មានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ និងវាយតម្លៃអំពីតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើឱ្យការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយសហការជាមួយអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក**. ដែលមានការពាក់ព័ន្ធ និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- រៀបចំផែនការសាងសង់ ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធានាឆ្លើយតបឱ្យបានទាន់ពេលវេលាទៅ

នឹងតម្រូវការនៃការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយសហការជាមួយអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ភ.** ដែលមានការពាក់ព័ន្ធ និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- រៀបចំប្លង់សាងសង់ និងបញ្ជីប៉ាន់តម្លៃនៃគម្រោងផ្សេងៗ ដើម្បីសុំការអនុម័តថវិកា សម្រាប់បម្រើឱ្យការងារសាងសង់
- រៀបចំសាងសង់ ឬជួសជុលទីកន្លែងសម្រាប់បម្រើឱ្យការព្យាបាលអ្នកជំងឺកូវីដ-១៩ និងការធ្វើចត្តាឡីស័កដោយធានាគុណភាពស្របតាមស្តង់ដារ និងនិយាមសំណង់ ដើម្បីឆ្លើយតបទៅសភាពការណ៍វិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ភ.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តមនាយឧត្តមសេនីយ៍ ខេង សុមេធ** អគ្គស្នងការរងនគរបាលជាតិ និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ភ.**។

**ប្រការ១៤**.-

អនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩ មានភារកិច្ច ដូចខាងក្រោម៖
- សហការ និងសម្របសម្រួលជាមួយគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ដើម្បីរៀបចំទីបូជា ឬទីបញ្ចុះសពអ្នកជំងឺកូវីដ-១៩ ដោយធានាបាននូវលក្ខខណ្ឌសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការបង្ការបាននូវការចម្លងមេរោគកូវីដ-១៩ ដល់អ្នកដទៃ
- ដឹកនាំ និងសម្របសម្រួលការគ្រប់គ្រង និងដឹកជញ្ជូនសាកសពអ្នកជំងឺកូវីដ-១៩ ទៅទីបូជាសព ឬទីបញ្ចុះសព ដោយសហការជាមួយមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- ដឹកនាំ និងសម្របសម្រួលជាមួយគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ក្នុងការគ្រប់គ្រងទីកន្លែងរៀបចំការបូជាសព ឬការបញ្ចុះសព ដែលត្រូវអនុវត្តទៅតាមនិយាមវប្បធម៌ ប្រពៃណី និងសាសនា ដោយត្រូវធានាបាននូវលក្ខខណ្ឌសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការបង្ការបាននូវការចម្លងមេរោគកូវីដ-១៩ ដល់អ្នកដទៃ និង
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់គណៈប្រតិបត្តិនៃ **គ.អ.ភ.**។

អនុគណៈកម្មការនេះ ដឹកនាំដោយ**ឯកឧត្តម កុល វីរក្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងមានអនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់។ សមាសភាពជាក់ស្តែងរបស់អនុគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានគណៈប្រចាំការនៃ **គ.ប.ភ.**។

**ប្រការ១៥**.-

អនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ភ.** អាចមានក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីអនុវត្តការងាររបស់ខ្លួន។ ក្រុមការងារទាំងនេះ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ភ.** តាមសំណើរបស់ប្រធានអនុគណៈកម្មការ។

អនុគណៈកម្មការនីមួយៗ អាចប្រើប្រាស់មន្ត្រីក្រោមឱវាទក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តភារកិច្ច។

**ប្រការ១៦ .-**

អនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក.** អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងផ្នែកឯកជននៅក្នុងការបំពេញការងាររបស់ខ្លួន។ គ្រប់ក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការដល់អនុគណៈកម្មការនីមួយៗក្នុងការបំពេញភារកិច្ចតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការប្រយុទ្ធទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

អនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក.** ត្រូវផ្តល់កិច្ចសហការចាំបាច់នានាឱ្យគ្នាទៅវិញទៅមក ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចរបស់អនុគណៈកម្មការនីមួយៗ។

អនុគណៈកម្មការនីមួយៗ និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ត្រូវផ្តល់ព័ត៌មានអំពីការងារប្រចាំថ្ងៃរបស់ខ្លួន ព្រមទាំងទិន្នន័យចាំបាច់នានាពាក់ព័ន្ធនឹងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជូនដល់លេខាធិការដ្ឋាននៃគណៈប្រតិបត្តិនៃ **គ.អ.ក.** ដើម្បីបូកសរុប និងរាយការណ៍ជូនថ្នាក់ដឹកនាំ។

**ប្រការ១៧ .-**

**គ.អ.ក.** ត្រូវរៀបចំការប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.អ.ក.** ឬតាមសំណើរបស់អនុប្រធាន **គ.អ.ក.** ឬតាមសំណើរបស់ប្រធានអនុគណៈកម្មការណាមួយ តាមការចាំបាច់។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអចិន្ត្រៃយ៍ អាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

គណៈប្រតិបត្តិនៃ **គ.អ.ក.** ត្រូវរៀបចំការប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ឬតាមសំណើរបស់អនុប្រធានគណៈប្រតិបត្តិនៃ **គ.អ.ក.** ឬតាមសំណើរបស់ប្រធានអនុគណៈកម្មការណាមួយ តាមការចាំបាច់។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអចិន្ត្រៃយ៍ អាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

**គ.អ.ក.** ឬគណៈប្រតិបត្តិនៃ **គ.អ.ក.** អាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, មន្ត្រីជំនាញ, អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំ ដើម្បីពិភាក្សា ឬពិគ្រោះយោបល់លើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងការងាររបស់គណៈកម្មការអន្តរក្រសួង។

**ប្រការ១៨ .-**

អនុប្រធាន និងសមាជិកអនុគណៈកម្មការនីមួយៗនៃ **គ.អ.ក.** ត្រូវចូលរួមកិច្ចប្រជុំរបស់អនុគណៈ-កម្មការនីមួយៗ តាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការទទួលបន្ទុក។ ក្នុងករណី ប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានដែលបានទទួលសិទ្ធិពីប្រធាន អាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន។

ប្រធានអនុគណៈកម្មការនីមួយៗនៃ **គ.អ.ក.** អាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, មន្ត្រីជំនាញ, អ្នកឯកទេស ឬផ្នែកឯកជន ចូលរួមប្រជុំ ដើម្បីពិភាក្សា ឬពិគ្រោះយោបល់លើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងការងាររបស់អនុគណៈកម្មការ។

**ប្រការ១៩ .-**

**គ.អ.ក.** និងអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក.** ប្រើប្រាស់ទីស្តីការក្រសួងសុខាភិបាល សម្រាប់កិច្ចដំណើរការនៃការអនុវត្តការងាររបស់ខ្លួន។

**គ.អ.ក.** និងអនុគណៈកម្មការនានាចំណុះឱ្យ **គ.អ.ក.** ប្រើកញ្ចប់ថវិកាជាតិ និងជំនួយផ្សេងៗពីដៃគូ

អភិវឌ្ឍន៍ និងសប្បុរសជន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ដើម្បីបំពេញការងាររបស់ខ្លួន។

**ប្រការ២០ .-**

រាល់យន្តការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រយុទ្ធ, ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលសេចក្ដីសម្រេចនេះចូលជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានយន្តការ និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**ប្រការ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ